**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមអ្នកសាងសង់កម្ពុជា**

# សេចក្តីជូនដំណឹង

សមាគមអ្នកសាងសង់កម្ពុជាសូមជូនដំណឹងដល់ក្រុមហ៊ុនប្រកបរបរអាជីវកម្ម សិក្សាគម្រោងប្លង់ និងក្រុមហ៊ុនគ្រប់ប្រភេទមេត្តាជ្រាបថា: សមាគមអ្នកសាងសង់កម្ពុជាទើបតែបានបង្កើតឡើងក្រោមការផ្តួចផ្តើមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ បានចុះបញ្ជីនៅក្រសួងមហាផ្ទៃលេខ ១៧១៦ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងសហព័ន្ធអ្នកសាងសង់អាស៊ាន **( ASEAN Constructors Federation )** បានបញ្ចូលនឹងចុះឈ្មោះសមាគមអ្នកសាងសង់កម្ពុជាជាសមាជិកពេញសិទ្ធិនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ នៅប្រទេសហ្វីលីពីន និងបានចូលជាសមាជិកសហព័ន្ធអន្តរជាតិនៃសមាគមអ្នកសាងសង់អាស៊ី និងប៉ាស៊ីហ្វិកខាងលិច នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅប្រទេសម៉ាឡេស៊ី។ សមាគមអ្នកសាងសង់កម្ពុជាសូមជម្រាបជូនដំណឹង និងផ្សព្វផ្សាយព័ត៌មានថា សមាគមបានរៀបចំចុះបញ្ជីឈ្មោះជាសមាជិកសមាគមអ្នកសាងសង់កម្ពុជាចាប់ពីពេលនេះហើយ។ ឆ្លៀតឱកាសនេះសមាគមអ្នកសាងសង់កម្ពុជាមានកិត្តិយលសូមជម្រាបជូន អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ និងអស់លោក-លោកស្រី ដែលជាប្រធានក្រុមហ៊ុនជ្រាបថា **ផលប្រយោជន៍** សម្រាប់ចូលជាសមាជិកសមាគមអ្នកសាងសង់កម្ពុជាមានដូចខាងក្រោម:

១- សមាគមនឹងធ្វើការការពារ និងសម្របសម្រួលការងារផ្សេងៗជូនសមាជិករបស់ខ្លួនតាមលទ្ធភាពដែលអាចធ្វើបាន ល្អឹកណាមានជនដ៏ទៃមករំលោភបំពានលើសិទ្ធិ និងកេងប្រវ័ញ្ចចំណេញផលប្រយោជន៍លើសមាជិករបស់សមាគម ។

២- ជួយធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុនសំណង់នានាទាំងក្នុងប្រទេស និងប្រទេសដែលជាសមាជិកសហព័ន្ធអ្នកសាងសង់អាស៊ាន ។

៣- ធ្វើឱ្យមានឱកាសអាចទំនាក់ទំនងជាមួយឈ្មួញក្នុងប្រទេសអាស៊ានតាមរយៈការប្រជុំនីមួយៗរបស់សហព័ន្ធអ្នកសាងសង់អាស៊ាន ។

៤- មានលទ្ធភាពពង្រីករបរអាជីវកម្មរបស់ក្រុមហ៊ុនទាំងនៅក្នុងស្រុក និងតាមបណ្តាប្រទេសជាសមាជិកអាស៊ាន ។

៥- អាចជ្រាបព័ត៌មាន និងស្គាល់ពីផលិតផល គម្រោងសាងសង់ និងការបណ្តាក់ទុនរបស់ក្រុមហ៊ុនដែលជាសមាជិកអាស៊ានក្នុងប្រទេសកម្ពុជា និងអាចជ្រាបពីតម្លៃឧបករណ៍ សម្ភារៈ បរិក្ខារ និងពលកម្មសំណង់នៅតាមបណ្តាប្រទេសអាស៊ាន ។

៦- ជួយផ្សព្វផ្សាយផលិតផលរបស់ក្រុមហ៊ុនទាំងនៅក្នុងស្រុក និងតាមបណ្តាប្រទេសអាស៊ាននៅពេលមានកម្មវិធីរបស់សហព័ន្ធអ្នកសាងសង់អាស៊ានដូចជា សិក្ខាសាលា សន្និសីទប្រជុំនៅក្នុងប្រទេស និងក្រៅប្រទេស ។ល។

៧- ជួយទិញ ឬលក់ផលិតផលរបស់ក្រុមហ៊ុនទៅឱ្យអតិថិជនទាំងក្នុងស្រុក និងតាមបណ្តាប្រទេសអាស៊ានដែលត្រូវការ ។

៨- អាចបញ្ជូនអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗរបស់សហព័ន្ធអ្នកសាងសង់អាស៊ាន សំដៅឱ្យមានស្តង់ដារអាស៊ានរួមតែមួយ ងាយស្រួលក្នុងការអនុវត្តន៍ការងារ និងមិនចាំបាច់ធ្វើការបញ្ជូន ឬចល័តអ្នកបច្ចេកទេសទៅមកនាំឱ្យមានការចំណាយច្រើន ។

៩- អាចទទួលបាន ឬផ្លាស់ប្តូរបច្ចេកទេស ឬបច្ចេកវិទ្យា និងបទពិសោធន៍នានាជាមួយបណ្តាប្រទេសអាស៊ាន ។

១០- ជួយសម្របសម្រួលបំពេញបែបបទស្នើសុំច្បាប់អនុញ្ញាតផ្សេងៗ ។

១១- រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ហើយជាកាតព្វកិច្ចចាំបាច់ត្រូវចូលរួមជាមួយសហព័ន្ធអ្នកសាងសង់អាស៊ានក្នុងនាមប្រទេសកម្ពុជា ជាសមាជិកក្នុងសហគមអាស៊ាន ។

## តារាងបង់ប្រាក់ភាគទាន

| ល.រ | ប្រភេទក្រុមហ៊ុនសំណង់ និងសិក្សាគម្រោងប្លង់ | ការចុះឈ្មោះ ចូលជាសមាជិក | សមាជិក កិត្តិយស | ប្រាក់ភាគទានប្រចាំខែ |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ |
| ១ | ប្រភេទី ១ | ១០០ USD | - | ៥០ USD |
| ២ | ប្រភេទី ២ | ១០០ USD | - | ៣៥ USD |
| ៣ | ប្រភេទី ៣ | ១០០ USD | - | ២៥ USD |
| ៤ | ក្រុមហ៊ុនផ្សេងៗ | ១០០ USD | - | ៥០ USD |

**<u>កំណត់ចំណាំ:</u>**

- ប្រភេទក្រុមហ៊ុនគឺពិនិត្យតាមការចុះបញ្ជីឈ្មោះប្រកបរបរអាជីវកម្មសាងសង់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- ក្រុមហ៊ុនផ្សេងៗដែលមិនមែនជាក្រុមហ៊ុនប្រកបរបរអាជីវកម្មសាងសង់ ហើយមានបំណងចូលជាសមាជិកសមាគមអ្នកសាងសង់កម្ពុជា ចាត់ទុកជាក្រុមហ៊ុនប្រភេទទី១ ទាំងអស់ ។
- សមាជិកទាំងអស់បង់ភាគទាន ៦ខែម្តង ឬ ១២ខែម្តង ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ និងអស់លោក-លោកស្រី** ប្រធានក្រុមហ៊ុនទាំងអស់អញ្ជើញចូលរួមចុះឈ្មោះជាសមាជិកសមាគមអ្នកសាងសង់កម្ពុជាឱ្យបានច្រើនកុះករដើម្បីជួយចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង ។

សូម **អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ និងអស់លោក-លោកស្រី** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ ២០១១

**ប្រធានសមាគម**

**ពុធ យាវសៃ**